ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

(ក.ស.វ.)

# ការសិក្សាពី

# គំរោងអភិវឌ្ឍន៍លំក្តខ្មែរ

## ធ្វើជាផលិតផលយុទ្ធសាស្ត្រ រយៈពេលមធ្យមនិងវែង

## សំរាប់រួមចំណែកកាត់បន្ថយភាពក្រីក្រ

ដើម្បី

គោរពជាក់ជូន

ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកម្មពិសេស

ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

តាមរយៈ - ឯកឧត្តម រដ្ឋមន្ត្រី ប្រធានក្រុមទី២

- ឯកឧត្តម អគ្គលេខាធិការនៃ ក.ស.វ.

ដោយ

កាំង តុង ហ៊ាង

សមាជិកអចិន្ត្រៃយ៍ ឋានៈស្មើរដ្ឋមន្ត្រី

(ទូរស័ព្ទ ០១២ ៩៥៤៤០៩ - ០៩០ ៣៣៤៤៤៥)

ចម្លងជូន :

ឯកឧត្តម អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

*"ដើម្បីមេត្តាជ្រាបជាព័ត៌មាន"*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**(ក.ស.វ.)**

# កំណត់បង្ហាញ

ខ្ញុំបាទឈ្មោះ **កាំង តុង ហ៊ាង** សមាជិកអចិន្ត្រៃយ៍នៃក.ស.វ.ប្រចាំក្រុមទី២

**សូមគោរពចូលមក**

**ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស**

**ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**តាមរយៈ :- ឯកឧត្តម ប្រធានក្រុមទី២**

**- ឯកឧត្តម អគ្គលេខាធិការនៃ ក.ស.វ.**

**កម្មវត្ថុ** : សំណើសុំដាក់ជូននូវការសិក្សាពីគំរោងអភិវឌ្ឍន៍ល័ក្ខខ្មែរ(Lac) ធ្វើជាផលិតផលយុទ្ធសាស្ត្រ រយះពេលមធ្យមនិងវែង សំរាប់រួមចំណែកកាត់បន្ថយភាពក្រីក្រ ។

**យោង** :- ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) លេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩

- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **ក.ស.វ.** លេខ ៤៤អនក្រ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០៩
- អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន **ក.ស.វ.** នាព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ ឱ្យរូបខ្ញុំបាទ ក៏ដូចសមាជិក**ក.ស.វ.**ម្នាក់ៗ មានភារកិច្ចសិក្សាពីគំរោងអភិវឌ្ឍន៍អ្វីមួយ ទោះរយះពេលមធ្យម ឬវែងក្តី ហើយដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងសំរេច ។

តាមសំណើក្នុងកម្មវត្ថុ និងអនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ដែលយោងខាងលើ ខ្ញុំបាទមានភារកិច្ចលើកជូនឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន**ក.ស.វ.** នូវមតិសិក្សារបស់រូបខ្ញុំបាទផ្ទាល់ ពីគំរោងអភិវឌ្ឍន៍ល័ក្ខខ្មែរ នៅទូទាំងប្រទេសកម្ពុជា ធ្វើជាផលិតផលយុទ្ធសាស្ត្រ រយះពេលមធ្យមនិងវែង សំរាប់រួមចំណែកកាត់បន្ថយភាពក្រីក្រ សមស្របតាមយុទ្ធសាស្ត្រចតុកោណដ៏ល្អប្រពៃរបស់រាជរដ្ឋាភិបាល នៅក្រោមការដឹកនាំដ៏ឈ្លាសវៃនៃ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សូមឯកឧត្តមប្រធានមេត្តាជ្រាបដូចខាងក្រោម :/

**១- ភាពចាំបាច់ដែល ក.ស.វ. ត្រូវចាត់ការសិក្សាពីសារប្រយោជន៍ និងភាពងាយស្រួលផលិតនៃល័ក្តខ្មែរ** ហើយជ្រើសរើសមណ្ឌលដកពិសោធន៍មួយ ដើម្បីឱ្យបានលទ្ធផលជាក់ស្តែង ធ្វើជាមូលដ្ឋានស្នើយោបល់ជូនទៅរាជរដ្ឋាភិបាល សូមឱ្យកំណត់គោលដៅយុទ្ធសាស្ត្រថ្នាក់ជាតិ ចំពោះដំណាំប្រភេទនេះ នៅក្នុងចំណោមប្រជាកសិករទូទាំងប្រទេស ៖

**១.១ : អំពីសារប្រយោជន៍នៃល័ក្តខ្មែរ :**

ល័ក្តខ្មែរគឺជាជ័រធម្មជាតិខះរឹងមួយប្រភេទ មានពណ៌ក្រហមព្រឿង ដែលកើតចេញពីសត្វល្អិតដូចស្រមោចហៅថា "**មេល័ក្ត ឬពូជល័ក្ត**" ដែលអ្នកផលិតល័ក្តមានវិធីចិញ្ចឹមទុក នៅចុងរដូវកាលនីមួយៗ សំរាប់ផលិតនៅដើមរដូវកាលបន្ទាប់ ។ នៅក្នុងសង្គមខ្មែរតាំងពីបុរាណកាលមក ល័ក្តខ្មែរមានសារប្រយោជន៍ក្នុងការប្រើប្រាស់ជាថ្នាំជ្រលក់ពណ៌សាច់ក្រណាត់ ដូចជាសូត្រ ហូល ផាមួង សារុង ជាដើម ទុកជាវត្ថុធាតុដើមពីធម្មជាតិសុទ្ធសាធ ដែលផលិតករសាច់ក្រណាត់បរទេសជាច្រើនបានកត់សំគាល់ថា មានគុណភាពខ្ពស់ជាងថ្នាំជ្រលក់ពណ៌ដែលផ្សំពីជាតិគីមី ។ ប៉ុន្តែ ទោះបីមានតម្រូវការជាលក្ខណៈឧស្សាហកម្មច្រើនក្តី ក៏គ្មានប្រភពផ្គត់ផ្គង់ជូនល្មមនៅកម្ពុជាទេ ពីព្រោះសង្គមខ្មែរមានវប្បធម៌ផលិតសំរាប់តែតម្រូវការក្នុងស្រុក ហើយរហូតមកទល់បច្ចុប្បន្ន អ្នកដែលយល់ដឹងពីវិធីចិញ្ចឹមនិងផលិតល័ក្ត នៅសល់តិចតួចគួរឱ្យបារម្ភ ។ ជាសក្ខីកម្មគឺ នៅបណ្តាឆ្នាំដំបូង បន្ទាប់ពីថ្ងៃរំដោះជាតិ ៧ មករា ១៩៧៩ ជាប្រវត្តិសាស្ត្រ មានឈ្មួញដើរប្រមូលទិញល័ក្តខ្មែរនៅតាមខេត្តនិងតំបន់ជនបទជាប់ព្រំដែន អាចដើម្បីតម្រូវការរបស់ប្រទេសជិតខាង ឬការនាំចេញបន្តទៅប្រទេសទីបីទៀត ។ ប៉ុន្តែ ក្នុងដំណាក់កាលបន្ទាប់រហូតមក ការដើរប្រមូលទិញនោះក៏អសកម្មស្ទើរទាំងស្រុងទៅវិញ នាំឱ្យខ្ញុំបាទយល់ថា គឺមកពីមូលហេតុនៃកង្វះការផ្គត់ផ្គង់ទំនិញសំរាប់តម្រូវការបរិមាណច្រើន ប៉ុន្តែពុំមានប្រភពផ្គត់ផ្គង់គ្រប់គ្រាន់នោះឯង ។

ក្រៅពីការប្រើប្រាស់ជាថ្នាំជ្រលក់ពណ៌ដូចខាងលើ សង្គមខ្មែរយើងនៅមានជំនឿនិងនិយមប្រើប្រាស់ល័ក្តខ្មែរសំរាប់លាយជាមួយទឹកក្តៅឬទឹកសុរា ដើម្បីផឹករំលាយភ្លាមៗនូវឈាមកក ពីក្នុងរាងកាយមនុស្សបានយ៉ាងឆុតឆាប់ នៅពេលរងគ្រោះថ្នាក់ធ្លាក់ពីទីខ្ពស់ ឬបុកទង្គិចខ្លាំង នាំឱ្យក្រាំគ្រាជាដើម ។ លើសពីនេះ ចំពោះដុំល័ក្តខ្មែរណាដែលតោងហើយធំធាត់ក្រឡឹងព័ទ្ធជុំវិញមែកឈើតូចណាមួយបាន នោះគេឱ្យឈ្មោះថា "**ល័ក្តជុំក្រឡង់**" ហើយគេមានជំនឿថា ដុំល័ក្តនោះគឺជាវត្ថុកម្រនិងស័ក្តិសិទ្ធិប្រចាំខ្លួននិងសង្គមគ្រួសារថែមទៀត ។ រីឯកាកសំណល់ល័ក្តខ្មែរ ក្រោយពីការស្ងោធ្វើទឹកពណ៌ជ្រលក់មួយលើកៗ ត្រូវបានគេពូតជាដុំតូចៗហើយខះរឹង ហៅថា "**អាចម៍ល័ក្ត**" ដែលក៏មានសារប្រយោជន៍ក្នុងការភ្ជួរកាំបិតផ្សេងៗកុំឱ្យរង្គោះរបូតក្នុងពេលប្រើ ដើម្បីបញ្ចៀសគ្រោះថ្នាក់ជាដើម ។

**១.២ : អំពីភាពងាយស្រួលក្នុងការផលិតល័ក្តខ្មែរ :**

នៅដើមរដូវកាលនីមួយៗ(តាមធម្មតាគឺនៅខែកុម្ភៈ ឬខែមីនា) គេគ្រាន់តែយកកូនស្លុកដែលបានចិញ្ចឹមទុកនូវពូជល័ក្តពីចុងរដូវកាលមុន ទៅចងភ្ជាប់នឹងមែកតូចៗនៃដើមឈើ ដែលពុំមែនជាដំណាំហូបផ្លែ រួមមានដូចជាដើមសង្កែ ដើមអំពិលបារាំង(ច័ន្ទគិរី) ដើមអង្គាដី ដើមក្ដុម្ពទេស(សម្បូរទេស)ជាអាទិ៍ រួចបង្ហើបមាត់ឬបើកគ្របកូនស្លុកនីមួយៗ ។ ចាប់ពីពេលនោះមេល័ក្តក៏ហើរចេញទៅទំលើមែកឈើតូចៗដែលនៅជុំវិញ រួចពង្រីកខ្លួនឱ្យធំធាត់ប៉ុនៗមេដៃឬមេជើង នៅព័ទ្ធមែកឈើមួយៗរហូតដល់ចប់រដូវកាល ជាពេលដែលត្រូវប្រមូលផលល័ក្តមកវិញ (តាមធម្មតាគឺនៅខែកក្កដា ឬខែសីហា : មានរយៈពេលប្រមាណ ៦ខែ) ដោយគេមិនចាំបាច់តាមដាន ថែទាំ បាញ់ថ្នាំការពារ ឬបំប៉នចំណីអាហារទៀងទាត់ ដូចក្នុងការចិញ្ចឹមមាន់-ទា ឬសត្វផ្សេងៗទៀតឡើយ ។ ម្យ៉ាងទៀត ដើមឈើដែលត្រូវផលិតល័ក្តខ្មែរគឺជាប្រភេទដែលមានដុះនៅស្ទើរគ្រប់ដំបន់ តួយ៉ាងដូចជាដើមសង្កែជាដើម ដែលដុះនៅតាមភ្លឺស្រែជាទូទៅនៅប្រទេសកម្ពុជា ។

នៅពេលត្រូវប្រមូលផលល័ក្ខនៅចុងរដូវកាលនិមួយៗ គេកាប់យកមែកសង្កែឬមែកឈើផ្សេងដែលមានល័ក្ខតោង មកប្រលេះយកផលទៅលក់ដូរ ដើម្បីយកមូលនិធិមកទ្រទ្រង់សេដ្ឋកិច្ចគ្រួសារបានយ៉ាងងាយស្រួល ដោយពុំចាំបាច់ចំណាយទុនច្រើនឡើយ ។ រីឯមែកឈើដែលនៅសល់ពីការប្រលេះយកល័ក្ខ ក៏មានផលក្នុងសេដ្ឋកិច្ចគ្រួសារ ជាឧសដុតចំអិនអាហារ ហើយរីឯមែកឈើធំដែលនៅជាមួយដើមឈើ ក៏មានឱកាសដុះលូតលាស់មែកខ្ចីថ្មីៗទៀត សំរាប់បំរើឱ្យការផលិតល័ក្ខនៅដើមរដូវកាលបន្តបន្ទាប់ជារឿយៗ ។

ខ្ញុំបាទនៅចាំបានថា មានអ្នកចិញ្ចឹមល័ក្ខខ្មែរជើងចាស់ម្នាក់ (ដែលស្លាប់ទៅហើយ សូមឱ្យស្គាល់) បាននិយាយប្រាប់ខ្ញុំបាទក្នុងន័យថា តាមពិសោធន៍របស់គាត់ គឺមានដើមសណ្តែកបារាំងមួយប្រភេទ ដែលពេលនោះគាត់ហៅថា "**ដើមកំប៉ិញ**" ពីព្រោះពូជរុក្ខជាតិនេះមានដើមទាបៗ ដូចសំពត់ខើចខ្ចី ប៉ុន្តែមានផ្លែច្រើនសំបើម ដែលជាចំណីមាន់-ទា ដ៏មានប្រសិទ្ធភាពបង្ការរោគផង ហើយមនុស្សក៏អាចហូបបានដូចប្រភេទគ្រាប់សណ្តែកដទៃទៀតផងដែរ ជាពិសេសគឺជាប្រភេទដំណាំដែលមេល័ក្ខតោងខ្លាំង ហើយផ្តល់ទិន្នផលនិងគុណភាពខ្ពស់ជាងល័ក្ខនៅមែកឈើផ្សេងទៀតទាំងអស់ ។ នៅពេលនេះ ខ្ញុំបាទយល់ឃើញថា គួរមានការសាកល្បងដាំ ដើម្បីយកលទ្ធផលនៃការពិសោធន៍ ហើយបើឃើញពិតដូច្នោះមែន នោះគឺជាលទ្ធភាពដែលនឹងនាំទៅដល់ការអភិវឌ្ឍដំណាំនេះជាទ្រង់ទ្រាយធំ ប្រសិនបើរាជរដ្ឋាភិបាលចាត់ការរកទីផ្សារនៅក្រៅប្រទេសបានទូលំទូលាយ សំរាប់ការនាំចេញ ។ ខ្ញុំបាទបានដៅទុករួចហើយ នូវលទ្ធភាពរកបានគ្រាប់ពូជសណ្តែកបារាំងនោះ កាលបើចាំបាច់ដាំជាកពិសោធន៍ ។

**១.៣ : អំពីថ្លៃល័ក្ខនៅលើទីផ្សារក្នុងស្រុក និងការព្យាករណ៍ពីប្រាក់ចំណូលក្នុងគំរោងផលិតល័ក្ខខ្មែរទូទាំងប្រទេស :**

តាមការស្រាវជ្រាវនៅលើទីផ្សារក្នុងរាជធានីភ្នំពេញ ថ្លៃល័ក្ខខ្មែរ សំរាប់តែតំរូវការជាប្រពៃណីក្នុងស្រុកគឺ ពី ៥០.០០០ រៀល ទៅ ៨០.០០០ រៀល ក្នុងមួយគីឡូក្រាម តាមប្រភេទគុណភាព ពោលគឺទាបជាងថ្លៃក្នុងការប្រមូលទិញនៅបណ្តាឆ្នាំដំបូង បន្ទាប់ពីថ្ងៃរំដោះជាតិ ៧ មករា ១៩៧៩ ជាប្រវត្តិសាស្ត្រ ដូចបានបញ្ជាក់ជូនខាងលើនោះ ។

ផ្តើមចេញពីថ្លៃអប្បបរមាខាងលើ ខ្ញុំបាទសូមធ្វើការគណនាដើម្បីប៉ាន់ស្មានទុកដូចតទៅ :

១.៣.១ : ស្ថិតិប្រជាជនត្រឹមដំណាច់ឆ្នាំ២០០៨ មានចំនួនប្រមាណ១៤.០០០.០០០នាក់ ហើយជាង៨០ភាគរយក្នុងនោះ ប្រកបមុខរបរកសិកម្ម ពោលគឺស្មើនឹង១១.២០០.០០០នាក់ ។

១.៣.២ : ប្រសិនបើមានប្រជាកសិករចំនួនប្រមាណតែ៣០ភាគរយនៃចំនួន១១.២០០.០០០នាក់ ដែលស្ម័គ្រចិត្តនិងមានលទ្ធភាពចិញ្ចឹមល័ក្ខខ្មែរ នោះអនាគតផលិតករសរុបមានប្រមាណ៣.៣៦០.០០០នាក់ ។

១.៣.៣ : ប្រសិនបើម្នាក់ៗផលិតល័ក្ខបានជាមធ្យមចំនួនតែ១០គីឡូក្រាម នោះឃើញថា បរិមាណល័ក្ខសរុបដែលផលិតបាន សំរាប់រដូវកាលនិមួយៗ មានចំនួនស្មើនឹង ៣៣.៦០០.០០០គីឡូក្រាម ។

១.៣.៤ : ដូច្នេះ ប្រាក់ចំណូលសរុបពីការផលិតល័ក្ខខ្មែររបស់ប្រជាកសិករក្រីក្រទូទាំងប្រទេស ឃើញស្មើនឹង : ៥០.០០០ រៀល x ៣៣.៦០០.០០០គ.ក្រ = ១.៦៨០.០០០.០០០.០០០ រៀល (មួយពាន់ប្រាំមួយរយប៉ែតសិបពាន់លានរៀល) ស្មើនឹងប្រមាណ ៤២០.០០០.០០០ USD (បើគិតតាមអត្រាប្តូរប្រាក់ ១USD = ៤.០០០ រៀល) សំរាប់មួយរដូវកាល ។

១.៣.៥ : តួលេខខាងលើនេះមិនទាន់គិតដល់នៅឡើយផងទេ នូវផលិតកម្មល័ក្ខខ្មែរជាទ្រង់ទ្រាយធំ ដែលរាជរដ្ឋាភិបាលអាចនឹងចលនាឱ្យវិនិយោគិននៅក្នុង និង/ឬក្រៅប្រទេសអភិវឌ្ឍខ្លាំងក្លាថែមទៀតតាមតំរូវការពីប្រទេសក្រៅ ប្រសិនបើមានការចាត់ចែងត្រៀវគរបាន ។

**១.៤ : អំពីការស្វែងយល់ ដើម្បីចងក្រងរក្សាទុកឡើងវិញ នូវវិធីចិញ្ចឹមឬផលិតល័ក្តខ្មែរ :**

ខ្ញុំបាទយល់ឃើញថា យើងអាចធ្វើការងារនេះបាន ដោយគ្រាន់តែចាត់ភ្នាក់ងារឱ្យទៅជួបអ្នកកំពុងចិញ្ចឹមល័ក្ត ឬចាស់ព្រឹទ្ធាចារ្យដែលនៅចេះចាំវិធីចិញ្ចឹមល័ក្តពិតប្រាកដ នៅមូលដ្ឋានផ្សេងៗឱ្យបានច្រើននាក់ ហើយសម្ភាសសុំការពន្យល់ច្បាស់លាស់ពីពួកគាត់ ។ ផ្តើមចេញពីព័ត៌មានទាំងនោះ ទើបយើងសរុប ហើយទាញយកការសន្និដ្ឋានជាសំយោគមួយ សំរាប់ការអនុវត្តដកពិសោធន៍ ដូចមានបញ្ជាក់នៅចំណុច២ខាងក្រោម ។ សូមឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានក.ស.វ.មេត្តាពិនិត្យនូវអត្ថបទសំណួរសំរាប់បទសម្ភាសន៍នោះ ដែលខ្ញុំបាទបានផ្តួចផ្តើមរៀបចំរួចហើយ ដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធស្រាប់ ។

នៅក្រោយពេលដែលមានការដកពិសោធន៍ទទួលបានលទ្ធផលជាវិជ្ជមាន ហើយរាជរដ្ឋាភិបាលសំរេចបញ្ចូលគំរោងអភិវឌ្ឍន៍ល័ក្តខ្មែរនេះទៅក្នុងផែនការយុទ្ធសាស្ត្ររបស់រដ្ឋ ដើម្បីកាត់បន្ថយភាពក្រីក្រ ក្រោយពីបានសំរេចការធ្វើឱ្យដៃគូពាណិជ្ជកម្មនៅលើពិភពលោកទទួលស្គាល់គុណភាព និងសារប្រយោជន៍របស់វត្ថុធាតុដើមពីធម្មជាតិប្រភេទនេះ ហើយចាប់ដៃឱ្យប្រទេសកម្ពុជាផ្គត់ផ្គង់តាមតំរូវការរបស់ប្រទេសមួយៗ នោះទើបយើងចាប់ផ្តើមចងក្រងឱ្យមានកូនសៀវភៅណែនាំពីវិធីឬរូបមន្តចិញ្ចឹមល័ក្តខ្មែរ ដើម្បីចែកជូនប្រជាកសិករនៅជនបទ ហើយចលនាកៀរគរពួកគេឱ្យចូលរួមចិញ្ចឹមឱ្យបានផុលផុសនៅទូទាំងប្រទេសតែម្តង ដោយរាជរដ្ឋាភិបាលចាត់តាំងក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ជាស្ថាប័នដើរតួបែងចែកពូជ និងដឹកនាំការអនុវត្តចិញ្ចឹមជាក់ស្តែង នៅដើមរដូវកាលទី១ រាប់បញ្ចូលទាំងវិធីទុកពូជល័ក្តនៅចុងរដូវកាលទី១នោះផងដែរ សំរាប់បន្តក្នុងរដូវកាលថ្មីៗ ប្រកបដោយនិរន្តរភាពតទៅ ។

**២- ការគួរដកពិសោធន៍ជំហានដំបូងរបស់ ក.ស.វ.**

ប្រសិនបើមានឆន្ទៈឬគោលដៅសាកល្បងដើម្បីស្វែងរកលទ្ធផលពិតប្រាកដ (វិជ្ជមានឬអវិជ្ជមាន) ដោយផ្អែកលើមតិផ្តួចផ្តើមក្នុងកំណត់បង្ហាញនេះ ខ្ញុំបាទយល់ឃើញថា **ក.ស.វ.** អាចចាប់ផ្តើមការងារឈានទៅធ្វើការអនុវត្តជាក់ស្តែង និងដកពិសោធន៍យកលទ្ធផលដំបូង នៅស្រុកព្រៃកប្បាស(ខេត្តតាកែវ) គួបផ្សំជាមួយការងារនយោបាយរបស់គណបក្ស ដែលសមាជិក **ក.ស.វ.** កំពុងទទួលបន្ទុក តាមកម្មវិធីសកម្មភាពជាលំដាប់លំដោយ ដូចតទៅ :

២.១ : នៅចុងឆ្នាំ២០០៩នេះ ចាត់ការឱ្យស្រង់ព័ត៌មានពីវិធីចិញ្ចឹមល័ក្តខ្មែរ នៅមូលដ្ឋានមួយចំនួន តាមរយៈបទសម្ភាសន៍ជាមួយអ្នកចិញ្ចឹមផ្ទាល់ ដើម្បីប្រមូលព័ត៌មានសំរាប់ការចិញ្ចឹមដកពិសោធន៍របស់**ក.ស.វ.** ។ ចំពោះការងារនេះ ប្រសិនបើ**ក.ស.វ.** មិនយល់ទាស់ទេ រូបខ្ញុំបាទផ្ទាល់ក៏អាចនឹងទទួលយកការចាត់តាំងបានដែរ ព្រោះបានត្រៀមអត្ថបទសំណួររួចហើយ ដូចខាងលើ ។

២.២ : នៅក្នុងឆ្នាំ២០១០ ចាត់ឱ្យប្រាស្រ័យទាក់ទង ធ្វើយ៉ាងណាឱ្យមានការទុកពូជល័ក្តពីមូលដ្ឋានចិញ្ចឹមល័ក្តផ្សេងៗ ឱ្យបានចំនួនសរុបធួនល្មមសំរាប់មួយឃុំព្រៃកប្បាស ឬបើមានលទ្ធភាព សំរាប់មួយស្រុកព្រៃកប្បាសតែម្តង ដើម្បីចែកលក់ឱ្យ **ក.ស.វ.** នៅចុងរដូវកាល ជាពេលប្រមូលផលល័ក្ត គឺនៅខែកក្កដា ឬ ខែសីហា ឆ្នាំ២០១០ ។

២.៣ : នៅដើមឆ្នាំ២០១១ ជ្រើសរើសប្រជាកសិករនៅឃុំឬស្រុកព្រៃកប្បាសមួយចំនួនធំ ដែលមានភ្លឺស្រែសម្បូណ៌ទៅដោយដើមសង្កែ ឱ្យចុះឈ្មោះក្នុងបញ្ជីអ្នកស្ម័គ្រចិត្តយកពូជល័ក្តទៅចិញ្ចឹម នៅពេលរដូវកាលថ្មីមកដល់ គឺនៅខែកុម្ភៈ ឬខែមីនា ។

២.៤ : នៅខែកុម្ភៈ និងខែមីនា ឆ្នាំ២០១១ ចាត់តាំងសមាជិក**ក.ស.វ.**ប្រចាំឃុំឬស្រុកព្រៃកប្បាសឱ្យដឹកនាំការយកពូជល័ក្តទៅចងនៅមែកសង្កែតាមភ្លឺស្រែឬក្នុងភូមិ ដោយមានកិច្ចជំនួយការពីអ្នកចេះចិញ្ចឹមដែលមាននៅមូលដ្ឋាននោះស្រាប់ ឬអ្នកចេះចិញ្ចឹម ដែលត្រូវពឹងពាក់មកពីតំបន់ផ្សេង ហើយជាប្រការល្អ គួរមានការចូលរួមពីភ្នាក់ងារកសិកម្មឃុំ ឬស្រុក ក្នុងក្របខ័ណ្ឌនៃកិច្ចសហការល្អជាបណ្តើរៗ ក្នុងការងារនោះ ។

២.៥ : នៅខែកក្កដា ឬខែសីហា ឆ្នាំ២០១១ ស្រង់យកទិន្នន័យនៃការប្រមូលផលល័ក្ខ ជាមួយនឹងវិធីទុកពូជល័ក្ខរបស់ប្រជាកសិករ ដើម្បីវាយតម្លៃ និងសន្និដ្ឋានចំពោះលទ្ធផលនៃការអនុវត្តដកពិសោធន៍នោះ ហើយរៀបចំអត្ថបទត្រិះស្តីពីវិធីចិញ្ចឹមនិងទុកពូជល័ក្ខ ដោយកែសំរួលឡើងវិញ ចេញពីអត្ថបទដែលកើតឡើងពីបទសម្ភាសន៍ជាមួយអ្នកចិញ្ចឹមល័ក្ខនានាពីខាងដើម គួបផ្សំជាមួយលទ្ធផលដកពិសោធន៍ផ្ទាល់របស់ក.ស.វ.នោះ ។

២.៦ : នៅខែសីហា ឬខែកញ្ញា ឆ្នាំ២០១១ ក្នុងករណីទទួលបានលទ្ធផលជាវិជ្ជមាន ធ្វើរបាយការណ៍និងស្នើយោបល់ជូនទៅរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើការពិនិត្យនិងសំរេចបើកទូលាយការអនុវត្តដកពិសោធន៍នេះ ទៅតំបន់ផ្សេងៗមួយចំនួនទៀត ជាជំហានទី២ ឬសំរេចបញ្ចូលក្នុងផែនការជាយុទ្ធសាស្ត្ររបស់រដ្ឋ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយកាត់បន្ថយភាពក្រីក្រតែម្តង អាស្រ័យលើលទ្ធផលនៃការទាក់ទងបានទីផ្សារជាមួយដៃគូពាណិជ្ជកម្មនៅក្រៅប្រទេស ។

២.៧ : សំរាប់ការសាកល្បងជំហានដំបូង ខ្ញុំបាទបានទាក់ទងទៅស្រុកសំបូរ ខេត្តក្រចេះ រួចហើយ ដើម្បីរកពូជល័ក្ខនៅចុងរដូវកាលត្រឹមខែសីហា ឆ្នាំ២០០៩ នេះ តែម្តង ។ ប្រសិនបើបាន គឺជាប្រការល្អសំរាប់ដកពិសោធន៍ទ្រង់ទ្រាយតូចបណ្តើរៗ នៅឃុំព្រៃកប្បាស មុនគេ នៅខែកុម្ភៈ ឬខែមីនា ឆ្នាំ២០១០ ខាងមុខ ។

**៣– កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ :**

ប្រសិនបើ**ក.ស.វ.**យល់ថាគួរអនុវត្តការដកពិសោធន៍ដែលស្នើឡើងនៅចំណុច២ ខ្ញុំបាទយល់ថា **ក.ស.វ.**ក៏គួរសុំកិច្ចសហប្រតិបត្តិការទន្ទឹមគ្នាជាបណ្តើរៗ ពីស្ថាប័នពាក់ព័ន្ធមួយចំនួននៅក្នុងប្រទេស ដូចខាងក្រោម :

**៣.១ : ក្រសួងសុខាភិបាល :** ដើម្បីសុំឱ្យជួយផ្តល់លទ្ធផលនៃការវិភាគសិក្សាតាមរយៈមន្ទីរពិសោធន៍ សំដៅឱ្យដឹងប្រាកដជាមុនថា :

៣.១.១ : តើល័ក្ខខ្មែរពិតជាមានប្រសិទ្ធភាពក្នុងការព្យាបាលជម្ងឺឈាមកកបានភ្លាមៗ ដូចការនិយមនិងជឿជាក់របស់សង្គមខ្មែរ តាំងពីបុរាណណាចារ្យមែនឬយ៉ាងណា ?

៣.១.២ : ក្រៅពីរោគប្រភេទនេះ តើល័ក្ខខ្មែរអាចត្រូវប្រើជាវត្ថុធាតុផ្សំសំរាប់ផលិតឱសថព្យាបាលរោគផ្សេងៗទៀតបានដែរឬទេ ?

៣.១.៣ : បើប្រៀបជាមួយថ្នាំជ្រលក់សាច់ក្រណាត់របស់ប្រទេសមួយចំនួន តើល័ក្ខខ្មែរមានគុណភាពកំរិតណា ?

ខ្ញុំបាទយល់ថា ការវិភាគសិក្សានេះចាំបាច់ណាស់ សំរាប់ឱ្យប្រទេសកម្ពុជាស្គាល់ទំនិញខ្លួនឯងច្បាស់លាស់ជាមុន ហើយលទ្ធផលនៃការវិភាគបានក៏មានសារប្រយោជន៍ធ្វើជាសក្ខីកម្ម ឱ្យឧស្សាហករឬផលិតករសាច់ក្រណាត់ខាងក្រៅប្រទេសយល់ដឹងល្អិតល្អន់អំពីល័ក្ខខ្មែរ ។

**៣.២ : ក្រសួងពាណិជ្ជកម្ម :** ដើម្បីសុំឱ្យជួយផ្សព្វផ្សាយឱ្យដៃគូពាណិជ្ជកម្មនៅក្រៅប្រទេសស្គាល់គុណភាពល័ក្ខខ្មែរ តាមគ្រប់មធ្យោបាយ(ដូចជាតាមវិធីផ្ញើល័ក្ខខ្មែរជាវត្ថុធាតុដើម សុំឱ្យរោងចក្រក្រណាត់ធំៗជួយសិក្សាពិសោធជាដើម) ជាពិសេសស្វែងយល់ពីថ្លៃនិងសេចក្តីត្រូវការល័ក្ខខ្មែរនៅលើទីផ្សារអន្តរជាតិជាបណ្តើរៗ តាមដែលអាចធ្វើបាន ពីព្រោះនេះជាកត្តាស្លាប់-រស់សំរាប់គំរោងដែលស្នើឡើង ពោលគឺប្រសិនបើមិនអាចរកទីផ្សារនាំចេញបានជាប្រចាំទេ នោះការពង្រីកផលិតកម្មល័ក្ខក្នុងស្រុកក៏មិនចាំបាច់ឡើយ ។

**៣.៣ : ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ :** ស្ថាប័ននេះនឹងមានតួនាទីចូលរួមជាសំខាន់ នៅក្រោយពេលដែលរាជរដ្ឋាភិបាលសំរេចបញ្ចូលការអភិវឌ្ឍដំណាំល័ក្ខខ្មែរ ទៅក្នុងផែនការសកម្មភាពកាត់បន្ថយភាពក្រីក្រ បន្ទាប់ពីក្រសួងពាណិជ្ជកម្មកំណត់បានសក្តានុពលនៃផលិតផលនេះ នៅលើទីផ្សារអន្តរជាតិ ។ តួនាទីនោះគឺការបំផុសចលនា

អភិវឌ្ឍល័ក្តខ្មែរនៅទូទាំងប្រទេសកម្ពុជា ប្រកបដោយនិរន្តរភាព ដោយសិក្សារកវិធីបង្កើនទិន្នផលនិងគុណភាពល័ក្តខ្មែរ ទៅតាមបច្ចេកទេសកសិកម្ម និងរ៉ាប់រងផ្គត់ផ្គង់ពូជល័ក្ត ដល់មជ្ឈដ្ឋានដែលបាត់បង់ម្ចាស់ការ នៅផុតពីការយកចិត្តទុកដាក់របស់ **ក.ស.វ.** តទៅទៀត ។

**៤- ការសន្និដ្ឋាន និងសំណូមពរ**

ជាការសន្និដ្ឋាន ខ្ញុំបាទយល់ឃើញថា សំណើរផ្តល់មតិដ៏ស្លូចស្តើងនេះអាចត្រូវបានចាត់ទុកជាគោលគំនិតដោយស្រមើស្រមៃមួយប៉ុណ្ណោះ ។ ប៉ុន្តែ បើពិតដូចការកត់សំគាល់របស់វិនិយោគិនខាងក្រៅក្នុងន័យថា ល័ក្តខ្មែរជាថ្នាំជ្រលក់ពណ៌ពីធម្មជាតិមានគុណភាពខ្ពស់ ដែលអាចជំនួសប្ញផ្សំជាថ្នាំជ្រលក់ពណ៌ដែលរោងចក្រផលិតសាច់ក្រណាត់លើពិភពលោកកំពុងប្រើប្រាស់បានមែន នោះឃើញថានឹងមានការផ្តល់ផលសេដ្ឋកិច្ចមួយកំរិតទៀត ឱ្យរដ្ឋប្រមូលបានប្រភពរូបិយប័ណ្ណជាមូលនិធិបំរុងរបស់ជាតិ សំរាប់ទ្រទ្រង់ជញ្ជីងពាណិជ្ជកម្មនិងជញ្ជីងទូទាត់ផង និងសម្រាប់បង្កើនសេដ្ឋកិច្ចគ្រួសារឱ្យប្រជាកសិករក្រីក្រនៅជនបទ ក្នុងក្របខ័ណ្ឌនៃការរួមចំណែកកាត់បន្ថយភាពក្រីក្រ សមស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលផង ។ម្យ៉ាងទៀត ប្រសិនបើគំរោងនេះទទួលបានការឧបត្ថម្ភគាំទ្រ និងលទ្ធផលជាវិជ្ជមានដូចការរំពឹងទុក នោះការស្រមើស្រមៃខាងលើក៏នឹងក្លាយទៅជាការពិត ដែលក៏នឹងដើរតួរសំខាន់ផងដែរ សំរាប់សម័យយុទ្ធនាការបោះឆ្នោតសាកល នៅឆ្នាំ២០១៣ខាងមុខ ។ ប៉ុន្តែទោះបីយ៉ាងណា ក៏គំរោងនេះរណបទៅនឹងការគាំទ្ររបស់រាជរដ្ឋាភិបាល ក៏ដូចទំនាក់ទំនងរបស់ក្រសួងពាណិជ្ជកម្ម ធ្វើយ៉ាងណាឱ្យដៃគូពាណិជ្ជកម្មជួយស្វែងយល់និងផ្សព្វផ្សាយពីគុណភាពល័ក្តខ្មែរ និងរណបទៅនឹងការកៀរគរបានសេចក្តីត្រូវការផលិតផលនេះ ពីខាងក្រៅមកប្រទេសកម្ពុជាជាប្រចាំ ។

ចំពោះរូបខ្ញុំបាទផ្ទាល់ បានជាសំរេចយកប្រធានបទខាងលើ នៅក្នុងគោលគំនិតដ៏ស្លូចស្តើងនេះ មកពីយល់ឃើញថា គំរោងអភិវឌ្ឍន៍ល័ក្តខ្មែរស្ថិតក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងក្នុងតួនាទីពិតៗនៃ**ក.ស.វ.** ព្រមទាំងសមស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្ត្រីដែលនៅក្នុងសេចក្តីយោងទៀតផង ។

អាស្រ័យហេតុនេះ សូមគោរពស្នើឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន**ក.ស.វ.** ទទួលពិនិត្យនិងសំរេច តាមការដ៏គួរតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩

ដោយគារវកិច្ចនិងភក្តីភាពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ :

**ហត្ថលេខា**

**ឈាំង ឆុន ហ៊ាន**

**<u>ចម្លងជូន :</u>**

**ឯកឧត្តម អគ្គលេខាធិការរាជរដ្ឋាភិបាល**

*" ដើម្បីមេត្តាជ្រាបជាព័ត៌មាន "*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធរបស់កំណត់បង្ហាញ

ចុះថ្ងៃទី ខែសីហា ឆ្នាំ២០០៩

ជូនឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន ក.ស.វ.

## អត្ថបទសំណួរសំរាប់បទសម្ភាសន៍ ជាមួយអ្នកកំពុងចិញ្ចឹមល័ក្តខ្មែរ និងចាស់ព្រឹទ្ធាចារ្យដែលចេះចាំច្បាស់ នូវការពិសោធក្នុងការងារនេះ

១- ខ្ញុំសូមបញ្ជាក់ថា មុននឹងចាប់ផ្ដើមបទសម្ភាសន៍ ភ្នាក់ងារដែលចង់បានព័ត៌មាន ត្រូវសន្ទនាជាមួយអ្នកដែលត្រូវឆ្លើយ នឹងសំនួរនិមួយៗ ធ្វើយ៉ាងណាឱ្យបានដឹងពីអត្តសញ្ញាណកម្មពិតរបស់គាត់ម្នាក់ៗ (នាម និងគោត្តនាម-ឈ្មោះភូមិ-ឃុំ-ស្រុក-ខេត្ត ដែលតាំងនៅ) និងថតសម្លេងទុកឱ្យបាន ហើយបើថតទាំងរូបបានទៀត កាន់តែប្រសើរ សំរាប់ការផ្សព្វផ្សាយ ឡើងវិញ នៅពេលអនាគត តាមការចាំបាច់ ។

២- សំណួរនានាដែលត្រូវប្រើក្នុងបទសម្ភាសន៍ រួមមានដូចខាងក្រោម :

សូមលោកអ៊ំ(ឬលោកតា-លោកយាយ-លោកពូ...តាមការជាក់ស្ដែង)មេត្តាជួយផ្ដល់ព័ត៌មានសំខាន់ៗ ស្ដីពីការ ចិញ្ចឹមល័ក្តខ្មែរយើង ដើម្បីទុកជាមេរៀនពិសោធន៍ឱ្យប្រជាកសិករនៅតំបន់ផ្សេងៗទៀត ឬប្រជាកសិករជំនាន់ក្រោយៗ រៀនសូត្រ តាមសំណួរមួយចំនួនដូចតទៅ :

### អំពីការផលិតល័ក្តខ្មែរ :

២.១ : នៅរដូវកាលចិញ្ចឹមល័ក្តនិមួយៗ តើគេចាប់ផ្ដើមនៅខែណា ? ហើយគេនឹងប្រមូលផលល័ក្តមកវិញនៅខែណា ? តើគេយកមេល័ក្តទៅធ្វើដូចម្ដេចខ្លះ នៅលើមែកឈើ ដែលត្រូវចិញ្ចឹមឱ្យមេល័ក្តនោះធំឡើង ? តើក្នុងមេល័ក្តមួយស្នុកតូច ឬមួយកន្ទោង គេចងសំរាប់តែមែកឈើតូចមួយ ឬសំរាប់មែកឈើច្រើននៅជុំវិញនោះ ? ជាទូទៅ ក្នុងដើមឈើមួយដើម គេត្រូវចងពូជល័ក្តប៉ុន្មានស្នុកតូច ឬកញ្ចប់តូច ? តើមែកឈើប៉ុនណាដែលគេត្រូវចងធ្វើមេល័ក្ត ហើយមែកឈើចាប់ពីប៉ុនណា ដែលគេមិនត្រូវធ្វើ ព្រោះមូលហេតុអ្វី ? តាមធម្មតា គេចិញ្ចឹមល័ក្តនៅលើមែកដើមសង្កែ តែក្រៅពីនេះ គេអាចចិញ្ចឹមលើ ដើមឈើប្រភេទណាខ្លះទៀត ហើយបានទិន្នផលដូចគ្នា ឬយ៉ាងណាវិញ ?

### អំពីការប្រមូលផលល័ក្តខ្មែរ :

២.២ : ដើម្បីប្រមូលផល តើគេត្រូវកាប់មែកឈើដែលមានល័ក្តតោង ឬឡើងដើមឈើដើម្បីបេះយកល័ក្តឬយ៉ាងណា ? នៅពេលបេះប្រមូលផលនោះ តើគេមានចាំបាច់ពាក់ស្រោមដៃការពារឬទេ ? បើគ្មានពាក់ តើល័ក្តដែលប៉ះដៃ មានដែលនាំឱ្យ កើតរមាស់ ឬរោគាអ្វីមួយទៀតឬក៏អត់ ? ក្រោយពីបេះ ឬប្រលេះយកបានហើយ ហើយទុកយូរកំរិតណាទើបល័ក្តនោះ ខូចគុណភាព ?